



# សេវាកម្មពិភពលោក
# របស់ជនជាតិអាមេរិក
# កាំងកាន់សាសនាជ្វីស

## ស្វែងរកយុត្តិធម៌សំរាប់សាកលលោក

## តាមរយៈការផ្លាស់ប្តូររបស់ប្រជាជននៅថ្នាក់ក្រោម




វាស់វែងការលូតលាស់ ពេទ្យពិនិត្យអ្នកជំងឺនៅអង្គការសង្គមសំរាប់ហារូបត្ថម្ភ ការអប់រំ និងសកម្មភាពសុខភាព ពិនិត្យកំពស់ឱ្យកុមារម្នាក់នៅប្រទេសឥណ្ឌា ។ រូបថតដោយ រ៉េបេកកា សុវ្រម៉ែន

MEASURES OF GROWTH A clinician at the Society for Nutrition, Education and Health Action checks the height of a child in India. PHOTO REBECCA S MAN

# ការប្តេជ្ញាចិត្តរបស់យើងក្នុងការផ្តល់ជំនួយ

ចាប់តាំងពីឆ្នាំ ១៩៨៥ **សេវាកម្មពិភពលោករបស់ជនជាតិអាមេរិកាំងកាន់សាសនាជ្វីស** ហៅកាត់ថា **អេ.ជេ.ដាប់បិលយូ.អែស** (AJWS) បានប្តេជ្ញាចិត្តក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍន៍ និងសិទ្ធិមនុស្សរបស់ប្រជាជនថ្នាក់ក្រោមនៅទ្វីបអាស៊ី អាហ្វ្រិក និងទ្វីបអាមេរិក ដោយមានការផ្តល់កម្លាំងចិត្តពីសំណាក់អ្នកគោរពសាសនាជ្វីសដើម្បីស្វែងរកយុត្តិធម៌ ។ តាមរយៈជំនួយរបស់យើងដែលបានផ្តល់ឱ្យអង្គការក្នុងស្រុកនានាទូទាំងទ្វីប AJWS ឈរជាមួយសហគមន៍ និងប្រជាជនទាំងអស់ដើម្បីឱ្យមានប្រសិទ្ធិភាពនៃការផ្លាស់ប្តូរ ។ នៅពេលដែលយើងភ្ជាប់ទំនាក់ទំនង និងគាំទ្រនូវកិច្ចខំប្រឹងប្រែងដ៏សម្បើមរបស់អ្នកដឹកនាំប្រជាជនថ្នាក់ក្រោម និងសកម្ម ជនផ្សេងៗ វាធ្វើឱ្យការងាររបស់យើង និងរបស់ពួកគេកាន់តែមានភាពខ្លាំងក្លាឡើងថែមទៀត ។

ដោយការផ្តល់នូវជំនួយដល់អង្គការនៅថ្នាក់សហគមន៍មូលដ្ឋាន អនុវត្តន៍ការងារនៅតាមជនបទដាច់ស្រយ៉ាល តំបន់ក្រីក្រនៅក្នុងទីក្រុង និងតំបន់ដែលមានជម្លោះ AJWS ជួយប្រជាជនដែលតំរូវការរបស់ពួកគេមិនត្រូវបាន ផ្តល់ឱ្យដោយការងារអភិវឌ្ឍតាមបែបប្រពៃណី ។ ជាញយៗដោយសារតែក្រុមទាំងនេះមិនសូវត្រូវបានរាប់រក ពីសំណាក់រដ្ឋាភិបាលក្នុងស្រុក និងសង្គម ការធ្វើការងារជាមួយពួកគេដោយចាំបាច់នោះគឺមានន័យថា ធ្វើយ៉ាងណាដាក់បញ្ចូលនូវការផ្តល់សេវាកម្មផ្សេងៗ និងការអភិវឌ្ឍន៍សហគមន៍ព្រមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីទាមទារនូវសេវាសាធារណៈ ធានាដល់ការគោរពសិទ្ធិមនុស្ស និងកាត់បន្ថយការរើសអើងជាដើម ។ ដៃគូរការងារ របស់យើងគឺមានគំនិតថ្មីៗ មានកាប្តេជ្ញា និងលើកទឹកចិត្ត។ ជារៀងរាល់ថ្ងៃ ពួកគេបង្កើតនូវដំណោះស្រាយចំពោះភាពក្រីក្រ និងការរើសអើង ហើយតស៊ូមតិដើម្បីការផ្លាស់ប្តូរ មិនត្រឹមតែនៅចំពោះបញ្ហាបន្ទាន់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើការនៅកំរិតកំពូលក្នុងស្ថាប័នរដ្ឋាភិបាលផងដែរ ។ ពួកគេពេញចិត្តចំពោះការងារដែលពួកគេធ្វើ និងរីករាយចំពោះជោគជ័យរបស់ពួកគេ ។ យើងមានមោទនភាព និងមានកិត្តិយសណាស់ក្នុងការចែករំលែកការងារនេះជាមួយអ្នកទាំងអស់គ្នា ។



| | |
|---|---|
| រូធស៍ ម៉េស៊ីងជ័រ | ខេត ក្រូជ័រ |
| អគ្គនាយក | នាយកកម្មវិធីជំនួយ |


ហុងឌូរ៉ាស់
សាធារណៈរដ្ឋ
ហ្កាណា
នីសេរ្សីយ៉ា
ឆាដ
ស៊ូដង់
អាហ្វហ្គានីស្ថាន
ប៉ាគីស្ថាន
សូម៉ាលី
ឥណ្ឌា
ម៉ិចស៊ិក
ភូមា
បង់ក្លាដែស
វៀតណាម
ហ្គាតេម៉ាឡា
ថៃ
អែល សាលវ៉ាឌ័រ
យូហ្គាន់ដា
ប៊ូឡាវ៉ី
ឥណ្ឌូនេស៊ី
កូលំប៊ី
រ៉ាវ៉ាន់ដា
អ៊ីធ្យូពៃ
កម្ពុជា
ប៉េរូ
បូលីវី
សិនេហ្គាល់
លីបេរីយ៉ា
ហ្សាមប៊ែ
ហ្ស៊ីមបាវ៉េ
កេនយ៉ា
MEXICO
HAITI
DOMINICAN REPUBLIC
HONDURAS
GUATEMALA
NICARAGUA
EL SALVADOR
COLOMBIA
PERU
BOLIVIA
SENEGAL
LIBERIA
GHANA
NIGERIA
CHAD
SUDAN
ETHIOPIA
SOMALIA
UGANDA
KENYA
D.R. CONGO
RWANDA
ZAMBIA
ZIMBABWE
AFGHANISTAN
PAKISTAN
BANGLADESH
INDIA
BURMA
VIETNAM
THAILAND
CAMBODIA
SRI LANKA
INDONES

# គោលការណ៍ និងយុទ្ធសាស្ត្រក្នុងការផ្តល់ជំនួយ




ការទ្រទ្រង់ជីវភាពរស់នៅ ការលក់ត្រីស្រស់នៅក្នុងប្រទេស ហ្កាណា

## គោលការណ៍ក្នុងការផ្តល់ជំនួយ

AJWS គាំទ្រដល់សហគមន៍ថ្នាក់ក្រោមដែលកំពុងធ្វើការបង្កើតពិភពលោកមួយឱ្យមានសមភាព និងយុត្តិធម៌ ។ ការងារនេះត្រូវបានដឹកនាំដោយគុណតម្លៃ និងបទដ្ឋាន ដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សថា : *"ដោយយល់ឃើញថា ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ហើយនិងការទទួលស្គាល់សិទ្ធិស្មើគ្នា និងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬ ដកហូតបាន ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។"*

## យុទ្ធសាស្ត្រក្នុងការផ្តល់ជំនួយ

AJWS ស្វែងរកបេសកកម្មនៃការផ្តល់ជំនួយរបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រដែលមានទំនាក់ទំនងគ្នាបួនយ៉ាងដូចជា:

**ជំនួយ:** AJWS ផ្តល់ដល់អង្គការក្នុងស្រុកជាមួយនឹងជំនួយរយៈពេលយូរអង្វែង ដែលប្រព្រឹត្តទៅលើសពីការគាំទ្រគំរោង ដើម្បីអាចជួយឱ្យក្រុមទាំងនេះអនុវត្តផែនការរបស់ពួកគេក្នុងការអភិវឌ្ឍសហគមន៍ និងផ្លាស់ប្តូរសង្គមបាន។

**ដៃគូរការងារ:** AJWS ស្វែងរកដៃគូរការងារយ៉ាងសកម្មជាមួយម្ចាស់ជំនួយ បណ្តាញអន្តរជាតិ និងអង្គការដទៃទៀត ដើម្បីសម្របសម្រួលដល់អ្នកទទួលជំនួយរបស់យើងទទួលបាននូវធនធាន ការបណ្តុះបណ្តាល និងស្ថាប័នបង្កើតគោល-

AJWS និងដៃគូរការងាររបស់ខ្លួនជឿជាក់យ៉ាងមុតមាំថាៈ

- អង្គការថ្នាក់ក្រោមគឺជាកន្លែងដែលប្រសើរបំផុត ដែលមានចក្ខុវិស័យ ភាពប៉ិនប្រសប់ និងអនុវត្តផែនការរបស់ខ្លួន ដើម្បីការអភិវឌ្ឍន៍សហគមន៍ និងប្រទេសរបស់ពួកគេ ។
- ការអភិវឌ្ឍន៍សហគមន៍មិនអាចធ្វើទៅបានឡើយ នៅពេលដែលសិទ្ធិមនុស្សត្រូវបានបដិសេធ ។
- ស្ត្រីគឺជាអ្នកដឹកនាំដ៏សំខាន់សំរាប់ដំណើរការអភិវឌ្ឍសហគមន៍ និងការផ្លាស់ប្តូរ។ ជីវិតសហគមន៍មិនអាចរីកលូតលាស់បានទេនៅពេល ដែលស្ត្រីមិនត្រូវបានពង្រឹងភាពម្ចាស់ការពេញលេញ ដើម្បីទប់ទល់នឹងអំពើហិង្សា និងការគាបសង្កត់ ។
- សហគមន៍ដែលមិនសូវត្រូវបានរាប់រក ដែលងាយរងគ្រោះដោយសារភាពក្រីក្រ និងការរំលោភសិទ្ធិមនុស្សគឺជាភ្នាក់ងារដ៏ខ្លាំងក្លានៃការផ្លាស់ប្តូរ និងការអភិវឌ្ឍន៍នៅពេលមានការចងក្រងពីខាងក្នុងសហគមន៍។

នយោបាយនានា ។ AJWS គាំទ្រអង្គការជាតិ និងអន្តរជាតិសំខាន់ៗតាមរយៈកម្មវិធីជំនួយនៃភាពជាដៃគូរការងារថ្នាក់មហាវិទ្យាល័យ (Collegial Partnership Grants Program) ។

**ការពង្រឹងសមត្ថភាពៈ** AJWS សម្របសម្រួលឱកាសផ្សេងៗដល់អ្នកទទួលជំនួយរបស់យើង ដើម្បីពង្រឹងសមត្ថភាពអង្គការរបស់ពួកគេ តាមរយៈកិច្ចសហការជាមួយអង្គភាពអ្នកស្ម័គ្រចិត្តរបស់ AJWS ដៃគូរសិក្សា អ្នកជំនាញការវាយតម្លៃ និងតាមដានចំពោះវគ្គបណ្តុះបណ្តាល ព្រមទាំងធ្វើការពង្រីកផ្នែកអ្នកផ្តល់ការពង្រឹងសមត្ថភាពក្នុងស្រុកតាមរយៈជំនួយទៅកាន់បណ្តាញផ្តល់វគ្គបណ្តុះបណ្តាល ប្រចាំប្រទេសទៀតផង ។

**ការតស៊ូមតិៈ** AJWS សម្របសម្រួលការដាក់បញ្ចូលនូវសំលេងរបស់ប្រជាជនថ្នាក់ក្រោមនៅក្នុងកិច្ចពិភាក្សាគោលនយោបាយថ្នាក់ជាតិ និងអន្តរជាតិ ។ យើងផ្តល់ជំនួយក្នុងការធ្វើដំណើរសំរាប់អ្នកទទួលជំនួយ ដើម្បីចូលរួមប្រជុំ និងវេទិកាធ្វើគោលនយោបាយសំខាន់ៗ ហើយក៏ផ្តល់ជំនួយដល់អង្គការដែលធ្វើការតស៊ូមតិថ្នាក់តំបន់ ដែលជួយជំរុញការគាំទ្រសំលេង និងជំនាញការរបស់អ្នកទទួលជំនួយ ព្រមទាំងសម្ព័ន្ធអង្គការរបស់ពួកគេបន្ថែមទៀត ។

# កម្មវិធីនៃការផ្ដល់ជំនួយ

AJWS គាំទ្រអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាននៅទ្វីបអាហ្វ្រិក អាស៊ី និងទ្វីប អាមេរិក ដោយធ្វើការផ្ដោតលើកម្មវិធីដូចតទៅ:

## ការទ្រទ្រង់ជីវភាពរស់នៅ និងការអភិវឌ្ឍន៍:

ជំនួយរបស់ AJWS ពង្រឹងសមត្ថភាពអង្គការថ្នាក់ក្រោម ដើម្បីឱ្យមាននិរន្តរភាពខាងផ្នែកសេដ្ឋកិច្ច និងបរិស្ថាន លើកកម្ពស់ស្តង់ដារការងារ ដែលមានភាពយុត្តិធម៌ ហើយលើកកម្ពស់ស្ថានភាពសង្គមរបស់ស្ត្រី និងសហគមន៍ដែលមិនសូវបានគេរាប់រក ។ ចំណុចអាទិភាពរួមមាន:

- ទ្រទ្រង់វិស័យកសិកម្ម ជីវៈចំរុះ និងសន្តិសុខស្បៀង ។
- ដីធ្លី និងសិទ្ធិប្រើប្រាស់ធនធាន
- ឱកាសខាងសេដ្ឋកិច្ច
- ការអភិវឌ្ឍន៍នៅក្នុងតំបន់ក្រីក្រ និងទីក្រុង

## សុខភាពសហគមន៍:

AJWS ជួយលើកកម្ពស់ស្តង់ដារសុខភាពសហគមន៍ ដោយបង្កើនការទទួលបានសេវផ្សេងៗ គាំទ្រការចូលរួមរបស់សហគមន៍ក្នុងការបង្ការ និងគ្រប់គ្រងមេរោគឆ្លង ហើយបញ្ឈប់អំពើហិង្សាផ្នែកយេនឌ័រ ។ ចំណុចអាទិភាពរួមមាន:

- ការបង្ការមេរោគអេដស៍ និងមេរោគផ្សេងទៀត ក៏ដូចជាការថែទាំ គាំទ្រ ការអប់រំ និងតស៊ូមតិ ។

## ការចូលរួមរបស់សហគមន៍នៅក្នុងសង្គ្រាម និងការកម្មវិធីសង្គ្រោះបន្ទាន់:

AJWS គាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ទទួលផលប៉ះពាល់ពីគ្រោះមហន្តរាយ សង្គ្រាម ដើម្បីឆ្ពោះទៅរកសន្តិភាព និងការអភិវឌ្ឍន៍ ។ ចំណុចអាទិភាពរួមមាន:

- ពង្រឹងការដឹកនាំសហគមន៍ជាតិ និងអន្តរជាតិ
- យកចិត្តទុកដាក់ ទទួលខុសត្រូវចំពោះគ្រោះ មហន្តរាយ និងកាត់បន្ថយគ្រោះថ្នាក់ ។
- ផ្ដល់នូវការគាំទ្រផ្នែកសង្គមសាស្ត្រ
- ការបញ្ឈប់ការប្រើប្រាស់អាវុធ ដកចេញនូវកំណែនកងទ័ព ការធ្វើសមាហរន្តកម្មអ្នកច្បាំង ជាពិសេសគឺកុមារ ។
- គាំទ្រការកសាងសន្តិភាព និងកិច្ចខិតខំប្រឹងប្រែង ពង្រឹងភាពម្ចាស់ការផ្នែកសេដ្ឋកិច្ច ពិសេសកម្មវិធី ដែលដឹកនាំដោយស្ត្រី និងយុវជន ។
- ដំណើរការឆ្លងកាត់ពីគ្រោះមហន្តរាយទៅរកការអភិវឌ្ឍន៍ តាមរយៈការលើកកម្ពស់ការទ្រទ្រង់ជីវភាពរស់នៅ សុខភាពសហគមន៍ និងការអប់រំសំរាប់អ្នកទាំងអស់គ្នា ។

- សុខភាពរបស់ស្ត្រី កុមារ និងសិទ្ធិមនុស្ស
- ពង្រឹងប្រព័ន្ធសុខាភិបាល
- ការបង្ការអំពើហិង្សា

**ការអប់រំសំរាប់ទាំងអស់គ្នា:** AJWS ផ្តល់ជំនួយក្នុងការពង្រឹងការអប់រំនៅសាលាសាធារណៈ អប់រំក្រៅប្រព័ន្ធ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់យុវជន និងយុវវ័យ ដែលត្រូវបានបង់បោះចោលពីសាលារៀន។ ចំណុចអាទិភាពរួមមាន:

- ពង្រីកការទទួលបានការអប់រំសំរាប់ក្មេងស្រី ក្មេងកំព្រា និងកុមារដែលទទួលផលប៉ះពាល់ដោយសារសង្គ្រាម ។
- លើកកម្ពស់គុណភាពអប់រំតាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន ការអភិវឌ្ឍន៍កម្មវិធីសិក្សា ការចូលរួមរបស់សហគមន៍ ព្រមទាំងការតាមដាននៅតាមសាលារៀន។
- គាំទ្រវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងអក្ខរកម្ម
- លើកកម្ពស់កម្មវិធីនៃការអភិវឌ្ឍន៍កុមារភាព ។

**សំលេងសហគមន៍-ការចូលរួមក្នុងភាពជាពលរដ្ឋ និងផ្នែកនយោបាយ:** AJWS គាំទ្រសហគមន៍ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីបង្កើតគោលនយោបាយ និងកម្មវិធីដែលជះឥទ្ធិពលដល់ការរស់នៅរបស់ពួកគេ។ ចំណុចអាទិភាពបំផុតនោះគឺ ការផ្តល់ដល់កិច្ចខិតខំប្រឹងប្រែង ដែលដឹកនាំដោយអង្គការក្នុងស្រុក ធ្វើការដើម្បីលើកកម្ពស់សិទ្ធិរបស់:

- ស្ត្រី
- កុមារ យុវជន និងមនុស្សពេញវ័យ
- ជនជាតិដើមភាគតិច
- ជនជាតិ និងអ្នកកាន់សាសនាភាគតិច
- អ្នកនិយមភេទដូចគ្នា
- ជនភៀសខ្លួន និងអ្នកដែលគេបណ្តេញចេញក្នុង តំបន់
- អ្នករស់នៅជាមួយមេរោគអេដស៍-ជំងឺអេដស៍
- ជនពិការ
- កសិករ និងកម្មករ



**ការពង្រឹងភាពម្ចាស់ការដល់ស្ត្រី** ក្មេងស្រីជនជាតិម៉ាយ៉ានចូលរួមនៅក្នុងព្រឹត្តិការណ៍ដែលរៀបចំដោយ FESIRGAU អ្នកទទួលជំនួយដែលធ្វើការដើម្បីបង្កើតភាពជាអ្នកដឹកនាំ និងសុវត្ថិភាពសំរាប់សហគមន៍ស្ត្រី និងក្មេងស្ត្រីជនជាតិដើមភាគតិចនៅ ហ្គូតាំម៉ាឡាកណ្តាល

# ការផ្តល់ជំនួយរបស់ AJWS នៅក្នុងទ្វីបអាមេរិក



សន្តិសុខស្បៀង ម្តាយម្នាក់ទ្រកូនរបស់គាត់ គ្រាប់ពោតលីងនៅ ផូខាតាំបូ ប្រទេស ប៉េរូ

ការងាររបស់ AJWS នៅក្នុងទ្វីបអាមេរិកធ្វើការនៅក្នុងប្រទេសចំនួន ១០ នៅក្នុងតំបន់ **ការីបៀន មេសូអាមេរិក** និងអាមេរិកខាងត្បូង ។ ជំនួយនៅក្នុងតំបន់ផ្តោតលើសិទ្ធិរបស់ជនជាតិដើមភាគតិច អម្បូរជនជាតិអាហ្វ្រូ ស្ត្រី និងយុវជន អ្នកនិយមភេទដូចគ្នា និងអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ ។

នៅប្រទេស **ម៉ិចស៊ិចកូ កូលំប៊ៃ ប៊ូលីវៀ ប៉េរូ** និង **ហុងឌូរ៉ាស់** AJWS គាំទ្រជនជាតិដើមភាគតិច និងអង្គការរបស់អម្បូរជនជាតិអាហ្វ្រូ នៅក្នុងការងាររបស់ពួកគេដើម្បីការពារដីធ្លីពីសល់ពីជំនាន់បុព្វបុរសរបស់ខ្លួន និងធនធានធម្មជាតិ ទប់ទល់នឹងគំរងឧស្សាហកម្មដែលមានទម្រង់ធំ ហើយយល់ដឹង

នៅ **ប៉េរូ ប៊ូលីវៀ** និង **ម៉ិចស៊ិចកូ** ក្រុមស្ត្រីថ្នាក់ក្រោមតស៊ូមតិប្រឆាំងនឹងគោលនយោបាយសុខភាពដែលមានភាពរើសអើង និងអំពើហិង្សាផ្អែកយេនឌ័រ ។ នៅ **អែលសាវ៉ាឌ័រ** និង **ហុងឌូរ៉ាស់** អ្នកទទួលជំនួយផ្តល់វគ្គបណ្តុះបណ្តាលដល់យុវជន និងដោះស្រាយបញ្ហាប៉ះពាល់ដល់អ្នកនិយមភេទដូចគ្នា ។

នៅក្នុងតំបន់ដែលមានអំពើហិង្សា និងសង្គ្រាម អ្នកទទួលជំនួយពី AJWS ធ្វើការជំរុញនូវជីវភាពរស់ នៅ សុខភាព ការអប់រំឱ្យមានភាពប្រសើរឡើង នៅខណៈពេលដែលកំពុងទាមទារឱ្យមានសន្តិភាព និងសន្តិសុខ ។ នៅ **កូលំប៊ី** ដៃគូរការងារចងក្រង មានការចូលរួមក្នុងភាពជាពលរដ្ឋ

ការងាររបស់ AJWS នៅក្នុងទ្វីបអាមេរិកធ្វើការនៅក្នុងប្រទេសចំនួន ១០ នៅក្នុងតំបន់ **ការីបៀន មេសូអាមេរិក** និងអាមេរិកខាងត្បូង ។ ជំនួយនៅក្នុងតំបន់ផ្តោតលើសិទ្ធិរបស់ជនជាតិដើមភាគតិច អម្បូរជនជាតិអាហ្វ្រូ ស្ត្រី និងយុវជន អ្នកនិយមភេទដូចគ្នា និងអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ ។

នៅប្រទេស **ម៉ិចស៊ិចកូ កូលំប៊ែ ប៊ូលីវៀ ប៉េរូ** និង **ហុងឌូរ៉ាស់** AJWS គាំទ្រជនជាតិដើមភាគតិច និងអង្គការរបស់អម្បូរជនជាតិអាហ្វ្រូ នៅក្នុងការងាររបស់ពួកគេដើម្បីការពារដីធ្លីពីសល់ពីជំនាន់បុព្វបុរសរបស់ខ្លួន និងធនធានធម្មជាតិ ទប់ទល់នឹងគំរោងឧស្សាហកម្មដែលមានទម្រង់ធំ ហើយយល់ដឹងយ៉ាងពេញលេញនូវសិទ្ធិសមោហភាពរបស់ពួកគេ ព្រមទាំងការចូលរួមក្នុងភាពជាពលរដ្ឋ និងក្នុងផ្នែកនយោបាយ ។

នៅប្រទេស **អែលសាលវ៉ាឌ័រ ម៉ិចស៊ិចកូ ហៃទី កូលំប៊ែ** និង **នីហ្គារ៉ាហ្គ័រ** គាំទ្រការផ្តួចផ្តើមគំនិតដែល អភិវឌ្ឍនិរន្តរភាពក្នុងវិស័យកសិកម្ម និងពាណិជ្ជកម្មក្នុងស្រុក ហើយតស៊ូមតិដើម្បីទទួលបានសិទ្ធិកាន់កាប់ដីធ្លី ជួយទប់ទល់ចំពោះការបំផ្លិចបំផ្លាញដោយសារ តែសេរីភាវូបនីយពាណិជ្ជកម្ម ការបំផ្លាញបរិស្ថាន និងការមិនយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះការធ្វើចំការជាលក្ខណៈតូចតាច ។

ប្រសិទ្ធភាព លទ្ធភាពទទួលបាន និងភាពចាំបាច់ចំពោះគុណភាពប្រព័ន្ធសុខភាព និងការអប់រំអាស្រ័យដោយមានការចូលរួមពីសំណាក់ស្ត្រី និងយុវជន។ នៅប្រទេស **ហ្គាតាំម៉ាឡា**ដៃគូរការងាររបស់អនុវត្តកម្មវិធីសិក្សាថ្នាក់មូលដ្ឋានដែលផ្តល់ការអប់រំភាសា និងវប្បធម៌ដែលមានគុណភាពខ្ពស់។

និងផ្នែកនយោបាយរបស់ប្រជាជនដែលត្រូវបានដេញចេញយុវជន ដែលត្រូវបានជាប់កំណែនកងពល ។ នៅ **ហៃទី ហុងឌូរ៉ាស់** និង **កូលំប៊ី** ដែលជាកន្លែងមានសង្គ្រាមជាញឹកញាប់កាន់តែមានភាពខ្លាំងឡើងដោយសារតែជម្លោះដីធ្លី និងធនធានផ្សេងៗ ។ ដៃគូរការងារ របស់ AJWS ធ្វើការដើម្បីស្តាបនាឡើងវិញនូវប្រព័ន្ធអេកូ (បរិស្ថានវិទ្យា) និងបង្កើតឱ្យមានសន្តិសុខក្នុងជីវភាពរស់នៅ ។

## ការឆ្លុះបញ្ចាំងរបស់អ្នកទទួលជំនួយ

សមាគមផលិករដើម្បីអភិវឌ្ឍសហគមន៍នៃ ឡា ស៊ីណាហ្កា ហ្វ្រែនដេ ដេល បាចូ ស៊ីនូ (ASPROSIG) គឺជាបណ្តាញថ្នាក់ក្រោមរបស់ កសិករ អ្នកនេសាទ ជនជាតិដើមភាគតិច ហ្សេនូ នៅកូលំប៊ែ ធ្វើការដើម្បីការពារបរិស្ថានធម្មជាតិ និងបង្កើតឱ្យមាននិរន្តរភាពខាងវិស័យកសិកម្ម ។ ដោយមានការគាំទ្រពី AJWS សមាគម ASPROSIG កំពុងអភិវឌ្ឍកម្មវិធីគ្រប់គ្រងដែនដីយ៉ាងទូលំទូលាយមួយ ដែលនឹងបង្កើតឱ្យមានចំការតូចៗបែបកសិបរិស្ថានវិទ្យា ចំនួន ១០០ ដើម្បី បង្កើនសន្តិសុខស្បៀងរបស់ប្រជាជនក្នុងតំបន់ និងបង្ការការបណ្តេញចេញក្នុងស្រុកផងដែរ ។

*"កិច្ចខិតខំប្រឹងប្រែងរបស់យើងបង្កើតឱ្យមាននូវទម្រង់នៃការអភិវឌ្ឍន៍ជនបទ ដែលវាជាវិធី យើងអាចការពារជីវិត និងធនធានធម្មជាតិ របស់យើងបាន....*

*យើងមានឫសគល់យ៉ាងជ្រៅនៅទីនេះ និងមានក្តីស្រលាញ់យ៉ាងធំធេងសំរាប់ប្រព័ន្ធធម្មជាតិរបស់យើង ។ ឫសគល់របស់បុព្វបុរសយើង និងទំនាក់ទំនងនៃអត្តសញ្ញាណ ជាមួយទន្លេ និងព្រៃលិចទឹក របស់យើងផ្តល់ជីវិតដល់ពួកយើង ។"*

***ចាមីនសិន ពីតាល្មឿ— សមាគម* ASPROSIG**

# ការផ្តល់ជំនួយរបស់ AJWS នៅក្នុងទ្វីបអាហ្វ្រិក

AJWS ធ្វើការនៅក្នុងប្រទេស ចំនួន ១៦ នៅអាហ្វ្រិកសាប់សាហារា (sub-Saharan Africa) ផ្តល់ជំនួយដល់អង្គការនានាដែលលើកកម្ពស់ការទទួលបានសេវាសុខ-ភាព អប់រំ និងគាំទ្រជីវភាពរស់នៅ ព្រមទាំងគាំទ្រឱ្យមានការលើកលែងដល់ ក្រុមដែលមិនបានទទួលអត្ថប្រ-យោជន៍ ។ ដោះស្រាយផលប៉ះពាល់នៃមេរោគអេដស៍-ជំងឺអេដស៍ និងលើកកម្ពស់សន្តិសុខសេដ្ឋកិច្ច និងស្បៀងសំរាប់បុគ្គលដែលបានឆ្លង និងត្រូវបានគេចម្លងមេរោគអេដស៍ គឺជាចំណុចចម្បងសំរាប់ AJWS ក្នុងការផ្តល់ជំនួយទូទាំងទ្វីប។ ដៃគូរការងាររបស់ AJWS នៅអាហ្វ្រិកខាងត្បូងកំពុងធ្វើការលើកកម្ពស់ការ ទទួលបាលនូវសេវាបង្ការថែទាំ និងព្យាបាល មេរោគអេដស៍ និងជំងឺអេដស៍ ។

អ្នកទទួលជំនួយនៅក្នុងប្រទេស **អ៊ីធីយ៉ូពា** **ហ្កេនយ៉ា** **យូហ្កាន់ដា** និង **ហ្សាំប៊ៃ** កំពុងធ្វើកម្មវិធីថែទាំផ្ទះ អាហារូបករណ៏ និងការគាំទ្រដទៃទៀតទៅដល់គ្រួសារ ដែលកំពុងរស់នៅជាមួយមេរោគ ហើយចិញ្ចឹមបីបាច់កុមារកំព្រា ។ នៅប្រទេស **នីហ្សេរីយ៉ា** និង **ហ្កាណា** ដៃគូរការងារធ្វើការផ្តល់ឱ្យអ្នកនិយមភេទដូចគ្នា ទទួលបានពតិមាន និងសេវាសុខភាព ។

ប្រមាណជា ៦០ភាគរយ នៃយុវវ័យកំពុងរស់នៅជាមួយមេរោគអេដស៍-ជំងឺអេដស៍នៅ **អាហ្វ្រិក** គឺជា ស្ត្រី និងក្មេងស្រី។ រចនាសម្ព័ន្ធនៃអំណាចមិនស្មើគ្នា និងការរើសអើងផ្នែកយេឌ័រ ធ្វើឱ្យពួកគេកាន់តែមានភាពងាយរងគ្រោះនៃការឆ្លង ហើយទទួលបន្ទុកចំពោះភាពក្រីក្រ អំពើហិង្សា និងភាពអយុត្តិធមិ យ៉ាងធ្ងន់ធ្ងរ ។



សុវត្ថិភាពសំរាប់ជនភៀសខ្លួន ទឹករបស់ក្មេងស្រ្តីបានមកពីជំរុំ IDP នៅទីក្រុង ចាតុនដូ ក្នុងប្រទេស លីប៊ីរីយ៉ា

នៅ **ហ្ស៊ីមបាវេ** និងនៅទូទាំងទ្វីប អ្នកទទួលជំនួយពីកំពុងបង្កើតឱ្យមានកម្មវិធីទ្រទ្រង់ជីវភាពរស់នៅសំរាប់ស្ត្រី និងផ្តល់ការគាំទ្រដល់អ្នក ដែលទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ។

ភាពរាំរ៉ៃអសន្តិសុខស្បៀងទុកឱ្យសហគមន៏គ្មានសម្លេងងាយរងគ្រោះចំពោះភាពអត់ឃ្លាន ការកេងប្រវ័ញ្ច និងការរំលោភបំពាន ។ ជំនួយនៅ តាមទីជនបទនៃប្រទេស **សេនេហ្កាល់** ផ្តោតលើ សកម្មភាពទ្រទ្រង់វិស័យកសិកម្ម ការគ្រប់គ្រងបរិស្ថាន និងការរកប្រាក់ចំណូលសំរាប់កសិករខ្នាតតូច ។

នៅប្រទេសដែលរងផលប៉ះពាល់ដោយសារសង្គ្រាម និងស្ថិតក្នុងអំឡុងពេលការបង្រួបបង្រួមឱ្យមានសន្តិភាព ដូចដែលបានឆ្លុះបញ្ចាំង នៅក្នុងជំនួយរបស់នៅប្រទេស **វ៉ាវ៉ាន់ដា** និង **លីបឺរីយ៉ា** ។

## ការឆ្លុះបញ្ចាំងរបស់អ្នកទទួលជំនួយ

អង្គការ ការអប់រំប្រៀបដូចជាឱសថ (ឬវ៉ាក់សុាំង) ប្រឆាំងមេរោគអេដស៏ ហៅកាត់ **អ៊ីវ៉ា** (EVA) បានក្លាយជាដៃគូរការងារជាមួយ AJWS តាំងពីឆ្នាំ ២០០៥ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលសុខភាពផ្លូវភេទ និងការបន្តពូជទៅដល់គ្រូបង្រៀននៅក្នុងរដ្ឋបីនៃប្រទេស **នីហ្សេ រីយ៉ា** ដែលមានអាត្រាឆ្លងមេរោគអេដស៏ខ្ពស់បំផុត ។ នៅឆ្នាំ ២០០៨ EVA បានសម្ពោធយុទ្ធនាការអប់រំកុមារងាយរងគ្រោះ និងកុមារកំព្រាដោយសារ មេរោគអេដស៏ (+OVC) នៅក្នុងសាលានិងនៅ ក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ ដោយសារជាផ្នែកមួយនៃការផ្តួចផ្តើមគំនិតនេះ EVA ធ្វើការស្រាវ ជ្រាវចងក្រង និងបោះពុម្ពផ្សាយពតិមានអំពី កត្តាដាក់កំរិតការទទួលបាននូវការអប់រំសំរាប់កុមារដែលផ្ទុកមេរោគអេដស៏ ហើយបង្កើតឱ្យសមត្ថភាពរបស់អ្នកថៃទាំ ដើម្បីគាំទ្រកុមារទាំងនេះដើម្បីឱ្យពួកគេត្រឡប់មកសាលារៀនវិញ ។

*"ខ្ញុំបានរៀនច្រើនណាស់នៅវគ្គនេះពីអ្នកគ្រូភាសាអង់គ្លេសរបស់ខ្ញុំ: គាត់បានធ្វើឱ្យខ្ញុំយល់ថាប្រសិនបើខ្ញុំចង់ក្លាយជាស្ត្រីដែលអស្ចារ្យ ខ្ញុំត្រូវតែកំណត់កត្តាចម្បងរបស់ខ្ញុំឱ្យត្រឹមត្រូវ ។ ខ្ញុំត្រូវធ្វើការច្រើនផ្តោតការយកចិត្តទុកដាក់លើសៀវភៅ និងមេរៀនរបស់ខ្ញុំ ដើម្បីនិយាយថាទេ និងមានន័យថាទេ ។"*

**កុមារី អីមងឹមប៊ី**

**អនុវិទ្យាល័យរដ្ឋ នៅរដ្ឋអីមបាវ៉ា បេនូ**

# ការផ្តល់ជំនួយរបស់ AJWS នៅក្នុងទ្វីបអាស៊ី




ការអប់រំសំរាប់ទាំងអស់គ្នា សិស្សានុសិស្ស នៅប្រទេស ភូមា

AJWS ធ្វើការនៅប្រទេសចំនួនប្រាំបី នៅទ្វីបអាស៊ី ផ្តល់ជំនួយដល់អង្គការដែលស្វែងរកភាពស្មើគ្នាសំរាប់ប្រជាជនក្រុមតូច អ្នកកាន់សាសនា និងអ្នកនិយមភេទដូចគ្នា ស្ត្រី កសិករខ្នាតតូច អ្នករស់នៅជាមួយ មេរោគអេដស៍ និងជំងឺអេដស៍ ហើយនិងក្រុមដែលគេបោះបង់ចោល។ AJWS បន្តគាំទ្រការស្តាបនាជាតិឡើងវិញនៅក្នុងងើបឡើងវិញពីការបំផ្លិចបំផ្លាញនៃ ព្យុះយក្សធីស៊ូណាមិកនៅឆ្នាំ ២០០៤ ដោយផ្តោតលើការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងតម្រូវការនៃការមិនផ្តល់សិទ្ធិក្នុងការបញ្ចេញសំលេង និងផ្តោតលើការកសាងឱ្យមានការងើបឡើងវិញរបស់សហគមន៍ក្នុងការត្រៀខ្លួនរៀបចំសំរាប់ការសង្គ្រោះបន្ទាន់នាពេលអនាគត ។ សន្តិសុខសិទ្ធិកាន់កាប់ដីធ្លី និងការគ្រប់គ្រងទៅលើធនធានធម្មជាតិគឺចំណុចចម្បងចំពោះការផ្តល់ជំនួយទ្វីបអាស៊ី ។ នៅប្រទេស **ឥណ្ឌា ថៃ** និង **កម្ពុជា** AJWS គាំទ្រជនជាតិដើម ភាគតិច សហគមន៍ដែលសង្គមមិនរាប់រក ដែលដំណើររបស់ពួកគេត្រូវបានគំរាមកំហែង ដោយសារគំរោងឧស្សាហកម្មខ្នាតធំដូចជា ការជីកយករ៉ែ ការកាប់ព្រៃឈើ ការសាងសង់ទំនប់វារីអគ្គិសនី និងការដាំដំណាំកសិកម្មសំរាប់នាំចេញ ។

ការផ្តល់ជំនួយនៅក្នុងប្រទេស **ឥណ្ឌា** និង **ថៃ** ដោះស្រាយភាពមិនស្មើគ្នាចំពោះកំរិតការងារ ការកេងប្រវ័ញ្ចកំលាំងពលកម្មក្នុងចំណោមសហគមន៍វណ្ណៈថ្នាក់ទាប និងជនអន្តោប្រវេសន៍ជាតិភូមាដែលប្រឈមមុខនឹងលក្ខខ័ណ្ឌការងារដ៏ប្រថុយប្រថាន ហើយត្រូវបានបដិសេធមិនផ្តល់ការ ការពារផ្នែកច្បាប់ ដែលសមស្រប ។ ជំនួយផ្តល់ដល់ការបើកវគ្គបណ្តុះបណ្តាលអំពីសិទ្ធិការងារ កំណែទម្រង់គោលនយោបាយការងារ ជំនួយផ្នែកច្បាប់ ព្រមទាំងសុវត្ថិភាព

និងសុខភាពការងារ ។

វាមានគ្រោះថ្នាក់ខ្លាំងនៅទ្វីបអាស៊ីចំពោះបញ្ហាអំពើ ហិង្សាការរើសអើងផ្នែកយេនឌ័រ និងផ្លូវភេទ។ អ្នកទទួលជំនួយនៅ **ឥណ្ឌា** ផ្តោតការយកចិត្តទុកដាក់ខាងសង្គមទៅកាន់តម្រូវការរបស់ក្មេងស្រីជំទង់ និងអ្នកដែលរួចផុតពីអំពើហិង្សាក្នុងគ្រួសារ ។ នៅប្រទេស **កម្ពុជា** ដៃគូរការងារ AJWS ធ្វើការកាត់បន្ថយអំពើហិង្សាផ្នែកយេនឌ័រនៅកន្លែងការងារ ជាពិសេសកម្មកររោងចក្រកាត់ដេរ និងអ្នករកស៊ីផ្លូវភេទ ។

នៅក្នុងតំបន់ឆ្លងកាត់ការបំផ្លិចបំផ្លាញដោយសារតែសង្គ្រាមអូសបន្លាយ អ្នកទទួលជំនួយ AJWS លើកកម្ពស់សង្គមស៊ីវិល។ យុទ្ធនាការរបស់កងទ័ពនៃការបោសសំអាតក្រុមប្រជាជនក្រុមតូចៗនៅភូមិភាគបូព៌ានៃប្រទេស **ភូមា** បានបន្សល់ប្រជាជនកន្លះលាននាក់ ដែលបានដេញចេញពីផ្ទះសម្បែងរបស់ពួកគេ ។ សង្គ្រាមរាប់ទសវត្សរ៍នៅប្រទេស **អាហ្វហ្គានី ស្ថាន** បានបំផ្លាញគ្រឹះស្ថានសុខភាព ការអប់រំ មធ្យោបាយសេដ្ឋកិច្ច ។ នៅប្រទេស **ស៊ីរីលង្កា** ការរីកធំ ឡើងនៃសង្គ្រាមស៊ីវិល បានបង្កើនឱ្យមានការបែងចែកនូវប្រជាជនក្រុមតូចៗ ។ នៅក្នុងបញ្ហាបន្ទាន់ ដែលមានភាពស្មុគស្មាញទាំងនេះ ដៃគូរការងាររបស់យើងធ្វើការផ្តល់នូវសេវាចាំបាច់ផ្សេងៗ និងកសាងមូលដ្ឋានគ្រឹះដើម្បីសន្តិភាព ។

## ការឆ្លុះបញ្ចាំងរបស់អ្នកទទួលជំនួយ

ក្រុមបណ្តាញសិស្សជនជាតិខារ៉ែន ហៅកាត់ **ខេអែសអិនជី** (KSNG) ដោះស្រាយគម្លាតនៃការ អប់រំនៅក្នុង ប្រទេស **ភូមា** ដោយសារតែសង្គ្រាម និងការបណ្តេញចេញ ហើយរៀបចំយុវជនដើម្បីក្លាយជា អ្នកដឹកនាំនាពេលអនាគតក្នុងភាពតស៊ូដើម្បីសេរីភាព និងលទ្ធិប្រជាធិបតេយ្យសំរាប់ប្រទេស **ភូមា** ។ ជាមួយនឹងជំនួយរបស់ AJWS KSNG ដឹកនាំគំរោងសាលាសំរាប់ជនជាតិខារ៉ែន ដែលត្រូវបានបណ្តេញចេញក្នុងតំបន់ ហៅកាត់ថា **ឃីដស៍** (KIDS) ដែលគាំទ្រសាលាក្នុងសហគមន៍ចំនួយប្រាំ នៅក្នុងរដ្ឋខារ៉ែន ហើយផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន សំភារៈអប់រំ សំលៀកបំពាក់សិស្ស និង សេវាសុខភាព ។

*"នៅពេលខ្ញុំរៀនថ្នាក់ទី៣ របបយោធាភូមាដុតភូមិរបស់យើង ហើយបង្ខំឱ្យពួកយើងចាញចេញ ។ នៅពេលខ្ញុំមានអាយុ ១២ឆ្នាំ បានធ្វើការជាកងទ័ព ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំមានឱកាសត្រឡប់ទៅសាលារៀនវិញតាមរយៈ KSNG ។ ខ្ញុំចង់ក្លាយជាមនុស្សម្នាក់ដែលមានប្រយោជន៍នៅក្នុងសហគមន៍ខ្ញុំ ។ ខ្ញុំមានបំណងបន្តការសិក្សារបស់ខ្ញុំ ហើយត្រឡប់មករដ្ឋខារ៉ែនវិញ ដើម្បីជួយតាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន ។"*

សិស្សចាស់អាយុ ១៨ឆ្នាំ នៃគំរោង KIDS

# កម្មវិធីជំនួយនៃភាពជាដៃគូរការងារថ្នាក់មហាវិទ្យាល័យ

តាមរយៈកម្មវិធីជំនួយនៃភាពជាដៃគូរការងារថ្នាក់មហាវិទ្យាល័យ AJWS បង្កើតភាពជាដៃគូរការងារជាមួយអង្គការថ្នាក់តំបន់ និងអន្តរជាតិ ដែលមានចិត្តដូចគ្នា ដោយសហការជាមួយអង្គការថ្នាក់ក្រោម រមែងតែជាវិធីនៃការជួយបំពេញបន្ថែមនូវ បេសកកម្មរបស់ AJWS ។

ជំនួយនៃភាពជាដៃគូរការងារថ្នាក់មហាវិទ្យាល័យគឺជាក្រុមចំរុះនៃការតស៊ូមតិ ការបណ្តុះបណ្តាលអន្តរជាតិ អង្គការសិទ្ធិមនុស្ស បណ្តាញអង្គការថ្នាក់ក្រោមប្រចាំតំបន់ ហើយក៏ជាអ្នកផ្តល់ជំនួយថ្មី និង តូចតាច ។ ពួកគេផ្តល់វគ្គបណ្តុះបណ្តាល ជំនួយ សហការជាមួយ និងតស៊ូមតិជំនួយឱ្យអង្គការសហគមន៍មូលដ្ឋាន (រាប់បញ្ចូលទាំងដៃគូរការងារ AJWS ជាច្រើនទៀត) ពង្រឹងសមត្ថភាពអ្នកក្នុងស្រុក ការគាំទ្រចលនាតស៊ូដើម្បីការផ្លាស់ប្តូរសាកលលោក ។ ជំនួយនៃភាពជាដៃគូរការងារថ្នាក់មហាវិទ្យាល័យបង្ហាញនូវជំនាញការនៅក្នុងផ្នែកផ្សេងៗ ដែលមានទំនាក់ទំនងជាមួយនឹងចំណុចអាទិភាពរបស់ AJWS រាប់បញ្ចូលទាំង សិទ្ធិរបស់ជនពិការ បញ្ហារបស់ស្ត្រី ការកាត់បន្ថយគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍ប្រជាជនថ្នាក់ក្រោម ។

មុខមាត់នៃការផ្លាស់ប្តូរ ក្មេងស្រីពីរនាក់កំពុងរស់នៅតំបន់ក្រីក្រ ក្នុងទីក្រុង មុំបៃ ប្រទេស ឥណ្ឌា



រូបថតដោយ រ៉េបេកកា ស្ស៊័រម៉ែន

ជំនួយទាំងនេះអាចឱ្យ AJWS ផ្តល់ធនធានបន្ថែមទៀតដល់អ្នកទទួលជំនួយ ធ្វើឱ្យកាន់តែស៊ីជម្រៅចំពោះមូលដ្ឋាននៃចំណេះដឹង និងជំនាញរបស់យើង ហើយគាំទ្រកំណែប្រែពិសេសៗនៅថ្នាក់តំបន់ និងអន្តរជាតិ ។

## ការឆ្លុះបញ្ចាំងរបស់អ្នកទទួលជំនួយ

**ទាន់ហេតុការណ៍:** មូលនិធិអន្តរជាតិដើម្បីការការពារក្រុមអ្នកការពារសិទ្ធិមនុស្ស ការពារ និងអប់រំសកម្មជនជំនួយមនុស្សធម៌ គ្មានហិង្សានៅក្នុងប្រទេស ចំនួន៩០ ។ AJWS ផ្តល់ជំនួយកម្មវិធីពង្រឹងសមត្ថភាព និងសន្តិសុខទាន់ហេតុការណ៍អន្តរជាតិ ដើម្បីក្រុមអ្នកការពារសិទ្ធិមនុស្ស ដែលលើកកម្ពស់ ការយល់ដឹងសន្តិសុខផ្ទាល់ខ្លួន ការថែរក្សាខ្លួន និង ប្រសិទ្ធិភាពនៃវិធានការការពារខ្លួន ហើយមានគោលបំណងកសាងគ្រួបង្គោលប្រចាំបណ្តាញថ្នាក់តំបន់ ដែលអាចផ្តល់ការគាំទ្រនៅពេលសកម្មជនត្រូវបានគំរាមកំហែង ។ AJWS ជារឿយៗណែនាំអ្នកទទួលជំនួយទៅកាន់វគ្គបណ្តុះបណ្តាលជំនួយ ទាន់ហេតុការណ៍ដែលចាំបាច់ ។

*"ពីម្សិលមិញខ្ញុំបានត្រឡប់មកពីកសិក្ខាសាលាស្តីពីគោលការណ៍សហគមន៍អឺរ៉ុបដើម្បីក្រុមអ្នកការពារសិទ្ធិមនុស្ស ។ ពួកយើងបានជួប និងទំនាក់ទំនងជាមួយអ្នកការទូតមកពីប្រទេសចំនួន ១៥ ក្នុងសហគមន៍អឺរ៉ុប ដែលមានភាពសកម្មលើបញ្ហាសិទ្ធិមនុស្ស ហើយបានរៀនពីវិធីសាស្ត្រក្នុងការទទួលបានការគាំទ្រនៅពេលមានវិបត្តិ ។"*

**អ្នកទទួលជំនួយពីAJWS និងអ្នកចូលរួមវគ្គបណ្តុះបណ្តាលជំនួយទាន់ហេតុការណ៍ នៅប្រទេសឥណ្ឌា**





សេវាកម្មពិភពលោករបស់ជនជាតិអាមេរិកាំងកាន់សាសនាជ្វីស  ហៅកាត់  AJWS គឺជាអង្គអភិវឌ្ឍអន្តរជាតិមួយ ដែលត្រូវបានលើកទឹកចិត្ត  ដោយអ្នកគោរពសាសនាជ្វីសធ្វើការស្វែងរកយុត្តិធម៌ ។ AJWS ឧទ្ទិសដល់ការជួយសម្រាលដល់ ប្រជាជនរស់នៅក្នុងភាពក្រីក្រ ភាពអត់ឃ្លាន  និងរស់នៅជាមួយមេរោគផ្សេងៗ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍  ដោយគ្មាន ការប្រកាន់ពូជសាសន៍ សាសនា និងជនជាតិអ្វីឡើយ ។  តាមរយៈការផ្តល់ជំនួយទៅដល់អង្គការថ្នាក់ក្រោម សេវាកម្មអ្នក ស្ម័គ្រចិត្ត ការតស៊ូមតិ និងការអប់រំ  AJWS លើកកម្ពស់សង្គមស៊ីវិល ការអភិវឌ្ឍន៍ដែលមាននិរន្តរភាព និងសិទ្ធិមនុស្សសំរាប់ អ្នកគ្រប់គ្នា នៅខណៈពេលដែលកំពុងលើកតម្កើងតម្លៃ និងការទទួលខុសត្រូវក្នុងភាពជាពលរដ្ឋទូទាំងសាកលលោក នៅក្នុង សហគមន៍ជ្វីស ។




**New York City**
45 West 36th Street
New York, NY 10018
t: 212.792.2900
800.889.7146
f: 212.792.2930

**San Francisco**
131 Steuart Street
Suite 200
San Francisco, CA 94105
t: 415.593.3280
f: 415.593.3290

**Washington, D.C.**
1001 Connecticut Avenue, NW
Suite 1200
Washington, D.C. 20036
t: 202.379.4300
866.531.9196
f: 202.379.4310

www.ajws.org/grants
ajws@ajws.org

ទីក្រុង ញូយ៉ក
៤៥ ទិសខាងលិច ផ្លូវទី ៣៦
ញូយ៉ក-អិនវ៉ាយ ១០០១៨
ទូរស័ព្ទ: ២១២.៧៩២.២៩០០
៨០០.៨៨៩.៧១៩៣០
ទូរសារ: ២១២.៩៧២.២៩៣០

ទីក្រុង សាន់ហ្វ្រាន់ស៊ីស្កូ
១៣១ ផ្លូវ ស្ទើអាត
ស៊្វីត ២០០
សាន់ហ្វ្រាន់ស៊ីស្កូ-ស៊ីអេ ៩៤១០៥
ទូរស័ព្ទ: ៤១៥.៥៩៣.៣២៨០
ទូរសារ: ៤១៥.៥៩៣.៣២៩០

ទីក្រុង វ៉ាស៊ីងតោន ឌីស៊ី
១០០១ ផ្លូវ ខូននិកធិខិត-
អិនដាប់បិលយូ - ស៊្វីត ១២០០
វ៉ាស៊ីងតោន-ឌី.ស៊ី.២០០៣៦
ទូរស័ព្ទ: ២០២.៣៧៩.៤៣០០
៨៦៦.៥៣១.៩១៩៦
ទូរសារ: ២០២.៣៧៩.៤៣១០


AMERICAN JEWISH WORLD SERVICE


**COVER** Schoolchildren, Democratic Republic of Congo. PHOTO MATTHEW EMRY
**INSIDE BACK COVER** Ghanaian women who participated in an animal husbandry microfinance project funded by AJWS grantee ICA Ghana. PHOTO LIZ VAISBEN